# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Mar-2011, 14:17
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរបស់ អៀង សារី ស្នើឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសម្បថ ប្រសិនបើត្រូវបានអនុញ្ញាតឲ្យផ្ដល់សក្ខីកម្មអំពីអ្វីដែលពួកគាត់បានដឹងពីរឿងក្ដីព្រហ្មទណ្ឌ

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) តទៅនេះសុំដាក់សំណើជូនអង្គជំនុំជម្រះសាលាដំបូង តម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យពួកគាត់ផ្តល់សក្ខីកម្មពីអ្វីដែលគាត់បានដឹងពីសំណុំរឿងក្តីព្រហ្មទណ្ឌ លើសពីការទាមទារដែលមាននៅក្នុងសំណាង។ សំណើនេះត្រូវតែធ្វើឡើងជាចាំបាច់ ដើម្បីប្រយោជន៍សច្ចភាព និងសង្គតិភាពនីតិវិធី។ ក.ស.ព បានចុះបញ្ជីរាយនាមដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវកោះហៅឲ្យផ្តល់សក្ខីកម្ម[1] ដើម្បី “បង្ហាញភស្តុតាងអំពីទ្រង់ទ្រាយដ៏ធំធេងនៃឧក្រិដ្ឋកម្មនានា និងអំពីទម្រង់ផ្សេងៗនៃការទទួលខុសត្រូវជាបុគ្គលខាងព្រហ្មទណ្ឌដែលបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឲ្យបានហួសពីវិមតិសង្ស័យ”[2]។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“CPC”) ចែងថា “ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចត្រូវគេស្តាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ”[3] ហើយវិធានផ្ទៃក្នុង (“វិធាន”) ក៏មិនបានចែងអ្វីពាក់ព័ន្ធនឹងបញ្ហានេះផងដែរ។ មេធាវីការពារក្តី សូមលើកឡើងថា CPC អាចរំលោភបំពានលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈការបង្ខំពួកគេឲ្យអនុវត្តជម្រើស Hobson[4]៖ គឺធ្វើការជ្រើសរើសរវាងការធ្វើសាក្សីផ្តល់សក្ខីកម្ម ឬតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ។ មេធាវីការពារក្តីគាំទ្រសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុង

---

[1] *រឿងក្តី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អ.ជ.ស.ជ ឧបសម្ព័ន្ធ៤ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរបស់ ក.ស.ព ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9/4.4 ERN: 00640830-00640835។

[2] *រឿងក្តី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អ.ជ.ស.ជ បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១ ទី២ ទី៣ ទី៣ក ទី៤ និងទី៥ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9/4 ERN: 00640669-00640676, កថាខណ្ឌ៨។ ដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីការពារក្តី នួន ជា ក៏បានចុះបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនជាសាក្សី គឺអ្នកដែលមានបំណងចង់ផ្តល់សក្ខីកម្មពីការដឹងឮពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ។ *រឿងក្តី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អ.ជ.ស.ជ បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់១, ២ក, ២ខ, ៣ក, ៣ខ, និង ៤ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E9/4/3 ERN: 00645265-00645270, កថាខណ្ឌ៨។ *រឿងក្តី នួន ជា* ០០២/១៩-០៩-២០០៧-អវតក-អ.ជ.ស.ជ, ឧបសម្ព័ន្ធគ: បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលភាគីមានបំណងស្នើសុំឲ្យកោះហៅ (សម្រាប់អ្នកដែលមិនស្នើសុំនូវវិធានការការពារ)-មេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E9/4/4.3, ERN: 00644444-00644444។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៣១២។

[4] ជាទូទៅ “ជម្រើស Hobson” ត្រូវបានសំដៅដល់កាលៈទេសៈដែលជម្រើសមិនមានន័យត្រូវបានផ្តល់ឲ្យ។ និយមន័យនេះមានពន្យល់នៅក្នុងវចនានុក្រម Oxford English ថា៖ “ជាជម្រើសទទួលយកនូវលក្ខខណ្ឌមួយដែលត្រូវបានផ្តល់ឲ្យ ឬមិនទទួលយកអ្វីទាំងអស់”។ និយមន័យនេះ អាច*រកបាន*នៅលើគេហទំព័រ៖

http://www.oed.com/view/Entry/32111?redirectedFrom=hobson“s%choice#eid9544746។

ការផ្តល់ចម្លើយពាក់ព័ន្ធនឹងបញ្ហាណាមួយនៅក្នុងរឿងក្តី ប៉ុន្តែសូមស្នើថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចឲ្យពួកគាត់ផ្តល់ចម្លើយ ដែលនេះជាទង្វើផ្ទុយនឹងច្បាប់ជាធរមាននៅកម្ពុជានោះ *ចាំបាច់*ត្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់សក្ខីកម្មក្រោមសម្បថ។

## I. ប្រវត្តិ៖ តួនាទីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តី00១

១. ក្នុងអំឡុងសវនាការសំណុំរឿងក្តី00១ ការមិនបានកំណត់ពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការ "គាំទ្រដល់ការចោទប្រកាន់"[5] បានបណ្តាលឲ្យមានការជជែកដេញដោល និងការរំខានជាច្រើនដល់កិច្ចដំណើរការ។ យោងការអះអាងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិចូលរួមក្នុងកិច្ចដំណើរការក្រោមវិធាន២៣(១) ត្រូវបានកំណត់ត្រឹមតែជាកាតព្វកិច្ចប៉ុណ្ណោះ "មិនសួរដដែលៗ ឬក៏សំណួរដែលវានៅក្រៅវង្វង់នៃអង្គហេតុ"[6]។ មេធាវីការពារក្តីរបស់ *ឌុច* បានបដិសេធចំពោះការលើកឡើងនេះ ដោយអះអាងថា "ដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់មិនមានតួនាទីអនុវត្តដូចគ្នាទៅនឹងតួនាទីរបស់សហព្រះរាជអាជ្ញានោះទេ។ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺមានលក្ខណៈខុសគ្នា...ដើមបណ្តឹងរដ្ឋប្បវេណីអាចគាំទ្រការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលបង្ហាញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ហើយពិរុទ្ធភាពនោះ គឺវាទាក់ទងទៅនឹងការឈឺចាប់របស់ជនរងគ្រោះ"[7]។

២. ការពិភាក្សាដេញដោលលើកដំបូង បានចាប់ផ្តើមភ្លាម នៅពេលដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើសុំធ្វើសេចក្តីសន្និដ្ឋានបទចោទ[8]។ សំណើនេះត្រូវបានសហព្រះរាជអាជ្ញា[9]

---

[5] វិធាន២៣(១) ចែងដោយសមហេតុផលថា៖ "គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖ ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់។

[6] *រឿងក្តី កាំង ហ្គេកអ៊ាវ* 00១/១៨-0៧-២00៧-អវតក/អ.ជ.ស.ជ ប្រតិចារិក ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២00៩ ឯកសារលេខ E1/35.1 ERN: 00344105-00344225 ទំព័រ៩៣។

[7] *ដូចឯកសារយោងខាងលើ* ទំព័រ៩៤-៩៦។

[8] *រឿងក្តី កាំង ហ្គេកអ៊ាវ* 00១/១៨-0៧-២00៧-អវតក/អ.ជ.ស.ជ សំណើសុំបន្ទាន់របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងសិទ្ធិរបស់ពួកគាត់ក្នុងការដាក់សេចក្តីសន្និដ្ឋាន នៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២00៩ ឯកសារលេខ E23 ERN: 00287870-00287876។

និងមេធាវីការពារក្តី[10]បដិសេធ និងច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូង[11]។ អង្គជំនុំជម្រះ-សាលាដំបូង បានផ្តល់សំអាងហេតុដោយគ្រាន់តែលើកឡើងថា វិធាន ឬ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានផ្តល់សិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស នោះទេ[12]។ អង្គជំនុំជម្រះបានលើកឡើងទៀតថា ការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានផ្តន្ទាទោសរបស់សហព្រះរាជអាជ្ញា អាចនឹងហួសពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការ "គាំទ្រដល់ការចោទប្រកាន់" [13]។

៣. នៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូង បានដាក់ចេញនូវអនុស្សារណៈមួយលើការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថាសេចក្តីថ្លែងការណ៍ត្រូវតែពាក់ព័ន្ធនឹងអង្គហេតុនានានៃសំណុំរឿងក្តី០០១ និងជាពិសេសទាក់ទិននឹងការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់ជនជាប់ចោទ "ត្រូវតែជាសំណួរពាក់ព័ន្ធនឹងអង្គហេតុនានាទាក់ទិនទៅនឹងការឈឺចាប់របស់ដើមបណ្តឹងរដ្ឋ-ប្បវេណី [sic]" [14]។

៤. នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ អង្គជំនុំជម្រះ បានគូសបញ្ជាក់ជាចុងក្រោយ ពីលក្ខណៈដាច់ដោយឡែកពីកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក និងបានទទួលស្គាល់ថា

---

[9] *រឿងក្តី កាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អវតក/អ.ជ.ស.ជ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើសុំបន្ទាន់របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) ទាក់ទិននឹងសិទ្ធិក្នុងការសន្និដ្ឋាននៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ ឯកសារលេខ E23/3 ERN: 00291070-00291075។

[10] *រឿងក្តី កាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អវតក/អ.ជ.ស.ជ ចម្លើយរបស់ក្រុមមេធាវីការពារក្តី ឆ្លើយតបទៅនឹងសំណើបន្ទាន់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម២) ទាក់ទិនទៅការធ្វើសេចក្តីប្រកាសបឋមមួយនៅក្នុងសវនាការអង្គ-សេចក្តី ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ ឯកសារលេខ E23/2 ERN: 00291063-00291065 (ភាសាបារាំង)។

[11] *រឿងក្តី កាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អវតក/អ.ជ.ស.ជ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើក ពេលសវនាការលើអង្គ-សេចក្តី ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ ឯកសារលេខ E23/4 ERN: 00293329-00293333។

[12] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ៤ កថាខណ្ឌ៧។

[13] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ៩។

[14] *រឿងក្តី កាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អវតក/អ.ជ.ស.ជ អនុស្សារណៈស្តីពីសវនាការលើការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ E115 ERN: 00358682-00358684 កថាខណ្ឌ៨។

លក្ខណៈគំរូដើមបណ្ដឹងរដ្ឋប្បវេណីតាមយុត្តាធិការច្បាប់ស៊ីវិល បានបង្កើតឡើង "សម្រាប់កិច្ចដំណើរការនីតិវិធីមិនស្មុគស្មាញ និងជនរងគ្រោះតិចតួច" [15]។ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា៖ "ដោយសារតែច្បាប់បង្កើត អ.វ.ត.ក និងលក្ខណៈនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមានកម្រិត ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវតែទទួលស្គាល់នោះ វាតម្រូវឱ្យមានការបកស្រាយក្នុងន័យចង្អៀត អំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធីចំពោះមុខ អ.វ.ត.ក"[16]។ ដើម្បីព្យាយាមបកស្រាយ ពីគោលបំណងនិងការកម្រិតនានាចំពោះសកម្មភាពដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូង បានបង្កើតនូវគោលការណ៍ដូចខាងនេះ ៖

ក. សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមមានទាំងសិទ្ធិប្រឈមមុខទៅនឹងអាជ្ញាធរចោទប្រកាន់តែមួយប៉ុណ្ណោះ[17]។

ខ. អត្ថន័យតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី គាំទ្រដល់ការចោទប្រកាន់ក្នុងវិធាន២៣(១) ត្រូវតែបកស្រាយឱ្យបានប្រុងប្រយ័ត្ន និង "មិនផ្ដល់សិទ្ធិទូទៅនៃការចូលរួមស្មើភាពគ្នាជាមួយសហព្រះរាជអាជ្ញានោះទេ" (ឬជាព្រះរាជអាជ្ញាបន្ថែមនោះទេ)[18]។

គ. ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានផ្ដល់សិទ្ធិឱ្យគាំទ្រដល់អយ្យការក្នុងការស្វែងរកការពិត និងកំណត់ធាតុផ្សំបទល្មើសព្រហ្មទណ្ឌ ទៅលើជនជាប់ចោទ ដែលប៉ះពាល់ទៅលើខ្លួន <u>គ្រាន់តែជា</u>មូលដ្ឋានសម្រាប់ទាមទារសំណងតែប៉ុណ្ណោះ[19]។

ឃ. ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសិទ្ធិក្នុងការធ្វើសេចក្ដីសន្និដ្ឋានអំពីការផ្ដន្ទាទោសទេ[20]។

---

[15] *រឿងក្ដី កាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អវតក/អ.ជ.ស.ជ សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស និងសេចក្ដីណែនាំទាក់ទិននឹងការសួរនាំជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឱ្យផ្ដល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ឯកសារលេខ E72/3 ERN: 00387022-00387047 កថាខណ្ឌ១២។

[16] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ១៣។

[17] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ២៦។

[18] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ២៥ -២៦។

[19] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ៣៣ (បញ្ជាក់បន្ថែម)។

[20] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ៣៤-៣៥។

ង. ដើមបណ្តឹងរដ្ឋប្បវេណី មិនមានសិទ្ធិក្នុងការតាំងសំណួរទៅកាន់សាក្សី អ្នកជំនាញ ឬជនជាប់ចោទ ជាផ្នែកមួយនៃការសាកសួរពីអត្តចរិតរបស់ជនជាប់ចោទ ដែលជាប់ទាក់ទិននឹងការផ្តន្ទាទោសទេ[21]។

៥. ក្នុងសំណុំរឿងក្តី00១ មានដើមបណ្តឹងរដ្ឋប្បវេណីតែចំនួន៩៣ ប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[22]។ នៅក្នុងសំណុំរឿងក្តី00២ នាពេលបច្ចុប្បន្ននេះ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២១២៣[23]។

## II. **ឧទ្ទិករណ៍**

### ក. **សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែកំហិតសម្រាប់តែការជួយជ្រោមជ្រែងទាមទារសំណងរបស់គាត់តែប៉ុណ្ណោះ**

៦. នៅក្នុងតុលាការជាតិកម្ពុជា សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អាចយកមកប្រើប្រាស់សម្រាប់សម្រេចលើការទាមទារសំណងរបស់ខ្លួនតែប៉ុណ្ណោះ[24]។ សាក្សីមួយរូបនៅក្នុងសវនាការ គឺជាបុគ្គលម្នាក់ដែលអាចផ្តល់សក្ខីកម្មអំពីបញ្ហាជាច្រើនពាក់ព័ន្ធនឹងសវនាការ ដូចជា អ្វីដែលសាក្សីបានឃើញ បានឮ ដោយផ្ទាល់ ឬបើមិនដូច្នោះទេ បានសង្កេតនូវអ្វីដែលសាក្សីបានដឹងពីអង្គហេតុមួយ (សាក្សីជំនាញមួយរូប) ឬជាទស្សនៈរបស់សាក្សី (ក្នុងឋានៈជាសាក្សីជំនាញម្នាក់ ឬជាសាក្សីស្តីពីបញ្ហាទាក់ទងនឹងអត្តចរិត)[25]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ មិនអាចត្រូវគេស្តាប់

---

21 *ដូចឯកសារយោងខាងមុន* កថាខណ្ឌ៤៥-៤៧។

22 *រឿងក្តី កាំង ហ្គេកអ៊ាវ* 00១/១៨-0៧-២00៧-អវតក/អ.ជ.ស.ជ សាលក្រមសំណុំរឿងក្តី00១ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២0១0 ឯកសារលេខ E188 ERN: 00572517-00572797 កថាខណ្ឌ៦៣៧។

23 *រឿងក្តី អៀង សារី* 00២/១៩-0៩-២00៧-អវតក/អ.ជ.ស.ជ ដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២0១0 ឯកសារលេខ D427 ERN: 00604508-00605246 កថាខណ្ឌ១២។

24 "ចៅក្រមស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី (ដែលជាធម្មតាក៏ជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មដែលចោទប្រកាន់ទៅលើជនជាប់ចោទដែរ) ដោយសារមានការខូចខាត ..." Stuart Coghill ប្រភពឯកសារសម្រាប់ច្បាប់ព្រហ្មទណ្ឌនៅកម្ពុជា International Human Right Law Group Cambodian Defenders Project ឆ្នាំ២000 ("ប្រភពឯកសារ") ផ្នែក៤.៤0។

25 *ដូចឯកសារយោងខាងលើ* ផ្នែក៤.0៧។

ចម្លើយក្នុងឋានៈជាសាក្សីបានទេ[26]។ ក្នុងឋានៈជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលមិនត្រូវផ្ដល់សក្ខីកម្ម ដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវធ្វើសម្បថនៅក្នុងតុលាការជាតិកម្ពុជាទេ[27]។

៧. ប្រទេសបារាំង ដែលប្រទេសកម្ពុជាបានយកប្រព័ន្ធច្បាប់ជាគំរូនោះ[28] អ្នកអះអាងឯករាជ្យមួយរូបក្នុងឋានៈជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ មិនអាចត្រូវគេស្ដាប់ចម្លើយជាសាក្សីបានទេ[29]។ ហេតុផលនៃការសម្រេចដូច្នេះគឺថា ដើមបណ្ដឹងរដ្ឋប្បវេណីមានចំណាប់អារម្មណ៍ចំពោះលទ្ធផលរបស់រឿងក្ដី ពោលគឺការសម្រេចពីពិរុទ្ធភាពមួយ អាចបណ្ដាលឲ្យការទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានជោគជ័យ។ ដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីមានលក្ខណៈលម្អៀង។

៨. ទាំងកិច្ចព្រមព្រៀង និងច្បាប់បង្កើតអ.វ.ត.ក[30] មិនបានចែងអ្វីទាំងអស់ ស្ដីអំពីការចូលរួមរបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ទោះបីជាវិធានផ្ទៃក្នុង ចែងថាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវជួយជ្រោមជ្រែងដល់សហព្រះរាជអាជ្ញា ប៉ុន្តែអត្ថន័យជាក់ច្បាស់ពីឃ្លា "គាំទ្រដល់ការចោទប្រកាន់" មិនទាន់កំណត់ឲ្យបានច្បាស់ទេ[31]។

៩. ពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការ វិធានផ្ទៃក្នុង គ្រាន់តែកំណត់ដោយចំហាពីសកម្មភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានកម្រិតចំពោះអត្ថប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួនតែប៉ុណ្ណោះ[32]។ សំណុំរឿងក្ដី០០១ កំណត់ថា "តម្រូវឲ្យមានការបកស្រាយក្នុងន័យ

---

[26] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៣១២។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣២៨ ចែងថា ការធ្វើសម្បថត្រូវធ្វើឡើងសម្រាប់តែសាក្សីប៉ុណ្ណោះ។

[28] *សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ១៣២១។ ក.ស.ច.ស ចែងថា "ច្បាប់កម្ពុជាមានឫសគល់ដោយផ្ទាល់មកពីច្បាប់បារាំង"។

[29] CATHERINE ELLIOTT, ច្បាប់ព្រហ្មទណ្ឌបារាំង ៣៣ (Willan Publishing, ឆ្នាំ២០០១)។

[30] មាត្រា៣៦ថ្មី នៃច្បាប់បង្កើត ផ្ដល់ឲ្យ "ជនរងគ្រោះ" នូវសិទ្ធិប្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[31] វិធាន២៣(១) ចែងដោយសមហេតុផលថា៖ "គោលបំណងនៃបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖ ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ ខ) ទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាន *២៣ស្ទួនបួន*។

[32] វិធាន៨០ស្ទួន(៤) ចែងថា៖ "[នៅសវនាការបឋម] អង្គជំនុំជម្រះសាលាដំបូង អាចណែនាំសហមេធាវីនាំមុខឲ្យផ្ដល់ខ្លឹមសារជាក់លាក់ស្ដីពីសំណង ដែលខ្លួនមានបំណងស្នើសុំ នៅក្នុងបណ្ដឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និង

ចង្អៀត អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធីចំពោះមុខ អ.វ.ត.ក"[33]។ ការបក-ស្រាយក្នុងន័យចង្អៀតមួយ ពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចផ្តល់សិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី គ្រាន់តែអាចនិយាយទាក់ទិនត្រឹមតែការទាមទារសំណងរបស់ខ្លួនប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងទទួលស្គាល់ថា "វាគ្មានមូលដ្ឋានផ្លូវច្បាប់ណាអោយអង្គជំនុំជម្រះសាលាដំបូង "កំណត់"ត្រឹមតែថាដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីឡើយ"[34]។ ចំពោះគោលបំណងនៃកិច្ចដំណើរការនីតិវិធី ទោះជានៅក្នុងក្រមនីតិវិធីរបស់កម្ពុជា[35] ឬក្រមនីតិវិធីរបស់បារាំងក្តី ចែងយ៉ាងច្បាស់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានតួនាទីគាំទ្រដល់ការចោទប្រកាន់ ហើយក្រមនីតិវិធីទាំងពីរនេះ មិនបានផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី នូវវេទិកាដើម្បីគាំទ្រជាសាធារណៈនូវ ពិរុទ្ធភាពរបស់ជនជាប់ចោទ លើសពីការបង្ហាញពីទំនាក់ទំនងរវាងសកម្មភាពរបស់ជនជាប់ចោទ និង ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[36]។

### ខ. ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្ម អំពីអ្វីដែលគាត់បានដឹងពីរឿងក្តីព្រហ្មទណ្ឌ ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ អាចផ្តល់សក្ខីកម្មបាន ដោយត្រូវធ្វើសម្បថ

---

សមូហភាព ក្នុងអំឡុងពេលមួយជាក់លាក់ ដែលបានកំណត់ដោយអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន២៣ស្ទួនបួន(៣)(ខ)។ នៅដំណាក់កាលក្រោយមកទៀត អង្គជំនុំជម្រះនឹងត្រូវកំណត់កាលបរិច្ឆេទចុងក្រោយ សម្រាប់សហមេធាវីនាំមុខ ក្នុងការដាក់បណ្តឹងទាមទារចុងក្រោយ សម្រាប់សំណងផ្លូវចិត្ត និងសមូហភាព"(បញ្ជាក់បន្ថែម)។

33 *រឿងក្តី កាំង ហ្កេកអ៊ាវ* ០០១/១៨-០៧-២០០៧-អវតក/អ.ជ.ស.ជ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទិននឹងការសួរនាំជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ឯកសារលេខ E72/3 ERN: 00387022-00387047 កថាខណ្ឌ១៣។

34 *រឿងក្តី នួន ជា ០០២/១៩-០៩-២០០៧-អវតក/អជសជ* សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខ សេចក្តីសង្ខេប និងគុណសម្បត្តិរបស់អ្នកជំនាញជាមួយចំណុចនៃដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ រួមមានទាំងឧបសម្ព័ន្ធសម្ងាត់ទាំងឡាយ អនុលោមតាមវិធាន៨០ ចុះថ្ងៃទី ២៣ កុម្ភៈ ២០១១ ឯកសារលេខ E9/8, ERN: 00646563-00646568 កថាខណ្ឌ ៨។

35 *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១៣-២៦, ៣៣៤-៣៥ ដែលផ្តោតទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះតែប្រយោជន៍ពាក់ព័ន្ធនឹងសំណងប៉ុណ្ណោះ។

36 សូមមើល Elliott ត្រង់ទំព័រ ៣២-៣៣។

១០. សម្បថបន្ថែមទម្ងន់ដល់សក្ខីកម្មរបស់សាក្សី។ អ្វីក៏ដោយដែលត្រូវបានផ្ដល់ដោយសម្បថ ដែលមានវិការៈដោយចេតនានោះ អាចនឹងធ្វើឲ្យសាក្សីប្រឈមជាមួយនឹងការផ្ដល់សក្ខីកម្មក្លែងក្លាយចំពោះតុលាការ។

១១. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា ដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រឹមតែនិយាយពាក់ព័ន្ធនឹងការទាមទារសំណងរបស់ខ្លួនប៉ុណ្ណោះ។ មេធាវីការពារក្ដី យល់ឃើញថា *ត្រូវតែ*គោរពទៅតាមច្បាប់ ទោះបីជាមានការទទួលស្គាល់វិសមភាពជាសក្ដានុពល ដែលដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនត្រូវទទួលរងក៏ដោយ។ សិទ្ធិនានារបស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានគោរពនោះទេ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះ ត្រូវធ្វើការជ្រើសរើសរវាងការធ្វើសាក្សីលើបញ្ហានានា ពាក់ព័ន្ធនឹងសំណុំរឿងក្ដីព្រហ្មទណ្ឌ និងការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ មេធាវីការពារក្ដី យល់ឃើញថា ប្រសិនបើចាំបាច់ ដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សី។ ប៉ុន្តែ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីត្រូវផ្ដល់សក្ខីកម្ម នោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះ មិនកម្រិតសក្ខីកម្មរបស់ខ្លួនត្រឹមតែការទាមទារសំណងរដ្ឋប្បវេណីទេ ប៉ុន្តែពួកគាត់ត្រូវផ្ដល់សក្ខីកម្មអំពីបញ្ហានានាពាក់ព័ន្ធនឹងសំណុំរឿងក្ដីព្រហ្មទណ្ឌផងដែរ។ ដូច្នេះ ត្រូវចាត់ទុកដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដូចជាសាក្សីមួយរូបផ្សេងទៀត ហើយត្រូវផ្ដល់សក្ខីកម្មដោយធ្វើសម្បថ។

១២. ដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (“ដីកា”) ចែងថា នៅក្នុងបញ្ជីឈ្មោះសាក្សីដែលខ្លួនមានបំណងស្នើសុំឲ្យកោះហៅ ភាគីអាចចុះឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី “ដែលខ្លួនមានបំណងស្នើសុំឲ្យកោះហៅដើម្បីមកធ្វើសេចក្ដីថ្លែងការណ៍ នៅក្នុងសវនាការ...ទៅលើអង្គហេតុ និង/ឬអ្នកមកធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងនឹងផលប៉ះពាល់ទៅនឹងបទល្មើសដែលបានចោទប្រកាន់”[37]។ អង្គជំនុំជម្រះសាលាដំបូង ហាក់បីដូចជាបានទទួលថា ដើម-បណ្ដឹងរដ្ឋប្បវេណី អាចនឹងមានលទ្ធភាពក្នុងការផ្ដល់សក្ខីកម្មលើបញ្ហាពាក់ព័ន្ធនឹងសំណុំរឿងក្ដីព្រហ្មទណ្ឌដែរ។ ប៉ុន្តែ ការធ្វើយ៉ាងដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីមានតួនាទីជាសាក្សី ជាជាងជាដើមបណ្ដឹងរដ្ឋប្បវេណី។ តាមរយៈដីកានោះ អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាយល់ព្រមឲ្យដើមបណ្ដឹងរដ្ឋប្បវេណីសន្មតតួនាទីខ្លួនជាសាក្សី។ ដីកានោះ ត្រូវបានដាក់ចេញក្រោមវិធាន៨០[38]។ វិធាន៨០ គ្រាន់តែអនុញ្ញាតឲ្យចុះបញ្ជីឈ្មោះ<u>សាក្សី</u> នៅក្នុងបញ្ជីឈ្មោះសាក្សីប៉ុណ្ណោះ មិនសំដៅលើ

---

[37] *រឿងក្ដី អៀង សារី* 00២/១៩-0៩-២00៧-អវតក/អ.ជ.ស.ជ ដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9 ERN: 00635754-00635759 កថាខណ្ឌ១(ii)។

[38] *ដូចឯកសារយោងមុន* បុព្វកថា។

ដើមបណ្តឹងរដ្ឋប្បវេណីទេ[39]។ ទោះបីជាមិនអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬវិធានផ្ទៃក្នុងក្តី មេធាវីការពារក្តីទុកបញ្ហានេះជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ថាតើដើម-បណ្តឹងរដ្ឋប្បវេណីអាចនឹងផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សី លើបញ្ហានានាពាក់ព័ន្ធនឹងសំណុំរឿងក្តីព្រហ្មទណ្ឌ ដែរឬយ៉ាងណានោះ។ ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី អាចផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីស្តីពីបញ្ហានានាពាក់ព័ន្ធនឹងសំណុំរឿងក្តីព្រហ្មទណ្ឌបាន នោះត្រូវចាត់ទុកដើមបណ្តឹងរដ្ឋប្បវេណី ជាសាក្សីមួយផ្សេងទៀត ពោលគឺផ្តល់សក្ខីកម្មដោយធ្វើសម្បថ និងត្រូវទទួលការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយ ប្រសិនបើមានចេតនាផ្តល់នូវសក្ខីកម្មមិនត្រឹមត្រូវ។

**អាស្រ័យហេតុនេះ** យោងសំអាងហេតុដូចបានរៀបរាប់ពីខាងលើ មេធាវីការពារក្តី សូមដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់សក្ខីកម្មក្រោមសម្បថ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ផ្តល់សក្ខីកម្មអំពីអ្វីដែលពួកគាត់បានដឹងឮ នៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌ លើសពីការទាមទារនៅក្នុងសំណាងរបស់ខ្លួននោះ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៤** ខែ**កុម្ភៈ** ឆ្នាំ **២០១១**

[39] វិធាន៨០(១) ចែងថា៖ "សហព្រះរាជអាជ្ញាត្រូវដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង នូវបញ្ជី ឈ្មោះសាក្សី រួមទាំងការបញ្ជាក់នូវទំនាក់ទំនងញាតិណាមួយដែលមានចែងក្នុងវិធាន២៤(២) និងអ្នកជំនាញដែលមានបំណងកោះហៅ ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាធរមាន" (បញ្ជាក់បន្ថែម)។